ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបែងចែកភាគលាភប្រចាំឆ្នាំ២០២០ ជូនភាគហ៊ុនិករបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** ជាធនាគារពាណិជ្ជទីមួយក្នុងប្រទេសកម្ពុជាដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ លិខិតលេខ ៧៨៤/២១ ន.ម.ក ចុះថ្ងៃសុក្រ ១១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ ស្តីពីការបែងចែកភាគលាភសម្រាប់ឆ្នាំ២០២០ របស់និយ័តករមូលបត្រកម្ពុជា និងលិខិតលេខ ធ៧-០២១-២៩១៩ ឆ.ត ចុះថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់ធនាគារជាតិនៃ កម្ពុជា ធនាគារ អេស៊ីលីដា ភីអិលស៊ី បានសម្រេចបែងចែកភាគលាភដែលនៅសល់សម្រាប់ប្រាក់ចំណេញឆ្នាំហិរញ្ញវត្ថុ ២០២០ ចំនួន **៤០.៣៦៧.៣២៩,២០ ដុល្លារអាមេរិក** ជូនភាគហ៊ុនិក ដែលពុំទាន់បានបែងចែកភាគលាភជូនសម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២០ តែប៉ុណ្ណោះ។

ធនាគារ អេស៊ីលីដា បានសម្រេចបែងចែកភាគលាភប្រចាំឆ្នាំហិរញ្ញវត្ថុ២០២០ ជូនភាគហ៊ុនិកទាំងនោះដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ប្រភេទភាគលាភដែលត្រូវបែងចែក | : | **សាច់ប្រាក់** |
| ២. រយៈពេលភាគលាភ | : | **ប្រចាំឆ្នាំ** |
| ៣.អនុបាតនៃការបែងចែកភាគលាភសរុប | : | **៣០%** |
| ៤. ភាគលាភដែលត្រូវបែងចែក | : | **៤០.៣៦៧.៣២៩,២០ ដុល្លារអាមេរិក** |
| ៥. ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : | **៣៩៩,២៦៧ រៀល** យោងតាមអត្រាប្តូរប្រាក់ផ្លូវការរវាងរូបិយប័ណ្ណដុល្លារអាមេរិកជាមួយប្រាក់រៀល របស់ធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ (៤.០៧០x០,០៩៨១) |
| ៦. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលភាគលាភ | : | **ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១** |
| ៧. កាលបរិច្ឆេទទូទាត់ភាគលាភ | : | **ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១** |

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនៅ **ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១**។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី **ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១**។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077
អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក ធនាគារ អេស៊ីលីដា តាមរយៈ៖

- **អាសយដ្ឋាន៖** អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh

- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១
**ធនាគារ អេស៊ីលីដា ភីអិលស៊ី**